**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**
លេខៈ ០០៤៤/ក.អ.ជ/១៥

ថ្ងៃពុធ ២ រោច ខែជេស្ឋ ឆ្នាំមមែ ព.ស.២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមិថុនា គ.ស ២០១៥

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រឡងជ្រើសរើសសិស្ស-និស្សិតឲ្យចូលបម្រើការងារ ជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ឆ្នាំ ២០១៥

ក្រសួងអភិវឌ្ឍន៍ជនបទ មានកិត្តិយសសូមជូនដំណឹងដល់សិស្ស-និស្សិតទាំង ០២ភេទ ដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ និងវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានា ឲ្យបានជ្រាបថា សម្រាប់ឆ្នាំ ២០១៥ នេះ ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវការជ្រើសរើសមន្ត្រីក្របខណ្ឌថ្មី (ក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ "**ប្រភេទ ក**") __**ចំនួន ៥០ រូប**__ ឲ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ "នៅទីស្តីការក្រសួង **ចំនួន ១៤រូប** និង តាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត **ចំនួន ៣៦រូប**"។

**១. លក្ខខណ្ឌជ្រើសរើស** : បេក្ខជនទាំង ០២ភេទ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១.១. ត្រូវមានសញ្ជាតិខ្មែរ

១.២. ត្រូវមានអាយុចន្លោះពី ១៨ ឆ្នាំ ដល់ ៣០ ឆ្នាំ (**កើតចាប់ពីថ្ងៃទី ០១ កញ្ញា ១៩៨៥ តមក**)

១.៣. ត្រូវមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ

**២. ទីកន្លែង និងសញ្ញាបត្រដែលត្រូវជ្រើសរើស** :

**ក. នៅទីស្តីការក្រសួង** : ត្រូវការជ្រើសរើសក្របខណ្ឌថ្មី ចំនួន **១៤ រូប** រួមមាន ÷

១. __នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក__ ចំនួន ០២ រូប :

- ការិយាល័យរដ្ឋបាល ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។
- ការិយាល័យបុគ្គលិក ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

២. __នាយកដ្ឋានអភិវឌ្ឍន៍ផែនការ និងទំនាក់ទំនងសាធារណៈ__ ចំនួន ០២ រូប :

- ការិយាល័យតាមដាន និងវាយតម្លៃ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ឬសេដ្ឋកិច្ច**។
- ការិយាល័យបច្ចេកវិទ្យាព័ត៌មាន ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**ព័ត៌មានវិទ្យា**។


អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្សី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

៣. <u>នាយកដ្ឋានបណ្តុះបណ្តាល និងស្រាវជ្រាវ</u> ចំនួន ០១ រូប :

- ការិយាល័យបណ្តុះបណ្តាល ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**អភិវឌ្ឍន៍ធនធានមនុស្ស ឬនីតិសាស្ត្រ**។

៤. <u>នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ</u> ចំនួន ០១ រូប :

- ការិយាល័យទឹកស្អាត ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**ទឹកក្រោមដី**។

៥. <u>នាយកដ្ឋានផ្លូវលំជនបទ</u> ចំនួន ០៥ រូប :

- ការិយាល័យកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។
- ការិយាល័យផែនការ និងស្ថិតិ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**ស្ថាបត្យករ ឬវិស្វករសំណង់**។
- ការិយាល័យត្រួតពិនិត្យ និងវាយតម្លៃ ចំនួន **០៣ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**វិស្វករប៉េភូគព្ភសាស្ត្រ ឬវិស្វករពិសោធន៍ដី**។

៦. <u>នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ</u> ចំនួន ០៣ រូប :

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។
- ការិយាល័យសហគ្រាសខ្នាតតូច ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សេដ្ឋកិច្ច ពាណិជ្ជសាស្ត្រ ឬទីផ្សារ**។
- ការិយាល័យរកទីផ្សារ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សេដ្ឋកិច្ច ឬទីផ្សារ**។

**ខ. នៅតាមមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត :** ត្រូវការជ្រើសរើសក្របខណ្ឌថ្មីចំនួន **៣៦ រូប** រួមមាន ÷

១. <u>មន្ទីរអភិវឌ្ឍន៍ជនបទរាជធានីភ្នំពេញ</u> ចំនួន ០១ រូប :

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

២. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល</u> ចំនួន ០១ រូប :

- ការិយាល័យផែនការ និងស្ថិតិ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច**។

៣. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកែប</u> ចំនួន ០១ រូប :

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

៤. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកោះកុង</u> ចំនួន ០១ រូប :

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

៥. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តក្រចេះ</u> ចំនួន ០១ រូប ៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

៦. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ចាម</u> ចំនួន ០២ រូប ៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គណនេយ្យ ឬហិរញ្ញវត្ថុ**។

៧. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ឆ្នាំង</u> ចំនួន ០១ រូប ៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

៨. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ធំ</u> ចំនួន ០១ រូប ៖

- ការិយាល័យអភិវឌ្ឍន៍សហគមន៍ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**អភិវឌ្ឍន៍ជនបទ សង្គមវិទ្យា ឬគ្រប់គ្រងធនធានមនុស្ស**។

៩. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ</u> ចំនួន ០១ រូប ៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

១០. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពត</u> ចំនួន ០១ រូប ៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

១១. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ</u> ចំនួន ០១ រូប ៖

- ការិយាល័យថែទាំសុខភាពជនបទ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**វិទ្យាសាស្ត្រ សុខាភិបាល ឬសុខភាពសាធារណៈ**។

១២. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្បូងឃ្មុំ</u> ចំនួន ០៨ រូប ៖

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។
- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គណនេយ្យ ឬហិរញ្ញវត្ថុ**។
- ការិយាល័យផែនការ និងស្ថិតិ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច**។
- ការិយាល័យផ្គត់ផ្គង់ទឹកជនបទ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**ទេពកោសល្យ ជនបទ ឬភូវិសាស្ត្រ ឬវិស្វករប័រិភ្ជគក្គសាស្ត្រ**។

- ការិយាល័យអភិវឌ្ឍន៍សហគមន៍ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**អភិវឌ្ឍន៍ជនបទ សង្គមវិទ្យា ឬគ្រប់គ្រងធនធានមនុស្ស**។
- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សេដ្ឋកិច្ច ឬធនាគារ ឬទីផ្សារ**។
- ការិយាល័យផ្លូវជនបទ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សំណង់ស៊ីវិល សំណង់ស្ពានថ្នល់ សំណង់ធារាសាស្ត្រ ឬទេពកោសល្យជនបទ**។
- ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកក្រូចឆ្មារ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ គ្រប់គ្រង អភិវឌ្ឍន៍ជនបទ សង្គមវិទ្យា ឬគ្រប់គ្រងធនធានមនុស្ស**។

១៣. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ</u> ចំនួន ០២ រូប :

- ការិយាល័យថែទាំសុខភាពជនបទ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**វិទ្យាសាស្ត្រសុខាភិបាល ឬសុខភាពសាធារណៈ**។
- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សេដ្ឋកិច្ច ឬធនាគារ ឬទីផ្សារ**។

១៤. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តប៉ៃលិន</u> ចំនួន ០១ រូប :

- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គណនេយ្យ ឬហិរញ្ញវត្ថុ**។

១៥. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង</u> ចំនួន ០១ រូប :

- ការិយាល័យផែនការ និងស្ថិតិ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច**។

១៦. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តពោធិ៍សាត់</u> ចំនួន ០២ រូប :

- ការិយាល័យផែនការ និងស្ថិតិ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច**។
- ការិយាល័យបណ្តុះបណ្តាល និងស្រាវជ្រាវ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬគ្រប់គ្រងធនធានមនុស្ស**។

១៧. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង</u> ចំនួន ០១ រូប :

- ការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សេដ្ឋកិច្ច ឬធនាគារ ឬទីផ្សារ**។

១៨. <u>មន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះវិហារ</u> ចំនួន ០១ រូប :

- ការិយាល័យផែនការ និងស្ថិតិ ចំនួន ០១ រូប។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច**។

១៩. មន្ទីរអភិវឌ្ឍន៍ជនបទខេត្តមណ្ឌលគិរី ចំនួន ០១ រូប :

- ការិយាល័យអភិវឌ្ឍន៍ជនជាតិភាគតិច ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**អភិវឌ្ឍន៍ជនបទ ឬគ្រប់គ្រងធនធានមនុស្ស**។

២០. មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី ចំនួន ០១ រូប :

- ការិយាល័យផ្លូវជនបទ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សំណង់ស៊ីវិល សំណង់ស្ពានថ្នល់ សំណង់ធារាសាស្ត្រ ឬទេពកោសល្យជនបទ**។

២១. មន្ទីរអភិវឌ្ឍន៍ជនបទខេត្តសៀមរាប ចំនួន ០១ រូប :

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។

២២. មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង ចំនួន ០៣ រូប :

- ការិយាល័យរដ្ឋបាល និងកិច្ចការទូទៅ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**នីតិសាស្ត្រ ច្បាប់ ឬរដ្ឋបាលសាធារណៈ**។
- ការិយាល័យផែនការ និងស្ថិតិ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គ្រប់គ្រង ហិរញ្ញវត្ថុ និងសេដ្ឋកិច្ច**។
- ការិយាល័យផ្លូវជនបទ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**សំណង់ស៊ីវិល សំណង់ស្ពានថ្នល់ សំណង់ធារាសាស្ត្រ ឬទេពកោសល្យជនបទ**។

២៣. មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្វាយរៀង ចំនួន ០១ រូប :

- ការិយាល័យថែទាំសុខភាពជនបទ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**វិទ្យាសាស្ត្រសុខាភិបាល ឬសុខភាពសាធារណៈ**។

២៤. មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ចំនួន ០១ រូប :

- ការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ ចំនួន **០១ រូប**។ បេក្ខជនត្រូវមានសញ្ញាបត្រផ្នែក**គណនេយ្យ ឬហិរញ្ញវត្ថុ**។

**៣. អំពីវិញ្ញាសាប្រឡង** : រួមមានវិញ្ញាសាសរសេរ និងវិញ្ញាសាផ្ទាល់មាត់ ÷

២.១. វិញ្ញាសាសរសេរ រួមមាន ÷

- វិញ្ញាសាវប្បធម៌ទូទៅ (**រយៈពេល ០២ ម៉ោង ចាប់ពីម៉ោង ៧:០០ នាទី-៩:០០ នាទីព្រឹក**)
- វិញ្ញាសាជំនាញបច្ចេកទេស (**រយៈពេល ០២ ម៉ោង ចាប់ពីម៉ោង ៩:៣០នាទី-១១:៣០ នាទីព្រឹក**)

២.២. វិញ្ញាសាផ្ទាល់មាត់ : សម្រាប់បេក្ខជនដែលប្រឡងជាប់វិញ្ញាសាសរសេរ។

**៤. កាលបរិច្ឆេទប្រឡង** :

- វិញ្ញាសាសរសេរនៅថ្ងៃអាទិត្យ **ទី ២៦ ខែកក្កដា ឆ្នាំ ២០១៥**។
- វិញ្ញាសាផ្ទាល់មាត់ នឹងជូនដំណឹងនៅពេលក្រោយ។

**៥. មណ្ឌលប្រឡង ៖**

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (វិញ្ញាសាសរសេរ)
- ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ (វិញ្ញាសាផ្ទាល់មាត់)

**៦. ទីកន្លែង កាលបរិច្ឆេទនៃការទទួលពាក្យ និងឈប់ទទួលពាក្យ ៖**

៥.១. កាលបរិច្ឆេទទទួលពាក្យ : ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ រៀងរាល់ពេលម៉ោងធ្វើការងារ ពេលព្រឹកចាប់ពីម៉ោង **០៧:៣០ - ១១:៣០នាទី** និងពេលរសៀលចាប់ពីម៉ោង **១៤:៣០ - ១៧:០០នាទី**)។

៥.២.កាលបរិច្ឆេទឈប់ទទួលពាក្យ : ថ្ងៃសុក្រទី **១៧ ខែកក្កដា ឆ្នាំ ២០១៥ វេលាម៉ោង ១៧:០០នាទី**។

៥.៣.ទីកន្លែងទំនាក់ទំនង ទទួលពាក្យ និងដាក់ពាក្យ : នៅនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក (ជាន់ផ្ទាល់ដី) ក្រសួងអភិវឌ្ឍន៍ជនបទ កាច់ជ្រុងវិថីលេខ ១៦៩ និងមហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់មិត្តភាព ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

**៧. បេក្ខជនត្រូវបំពេញសំណុំលិខិតក្នុងការដាក់ពាក្យប្រឡង រួមមាន ៖**

| | |
|---|---|
| ៧.១. ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| ៧.២. សេចក្តីចម្លងសញ្ញាបត្រដោយមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច | ចំនួន ០១ ច្បាប់ |
| ៧.៣. ជីវប្រវត្តិសង្ខេបមានបិទរូបថត (៤ គុណ ៦) | ចំនួន ០២ ច្បាប់ |
| ៧.៤. សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ចំនួន ០១ ច្បាប់ |
| ៧.៥. សលាកបត្រឯកត្តជន | ចំនួន ០៣ ច្បាប់ |
| ៧.៦. កិច្ចសន្យាបម្រើការងារក្រសួង | ចំនួន ០៣ ច្បាប់ |
| ៧.៧. បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង | ចំនួន ០២ ច្បាប់ |
| ៧.៨. រូបថតថ្មី ៤ គុណ ៦ ថតចំពីមុខ | ចំនួន ០២ សន្លឹក |

**សេចក្តីបញ្ជាក់ ៖**

- **បេក្ខជន** ជាជនពិការ និងស្ត្រី ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្តល់ជាអាទិភាព
- **បេក្ខជន** ត្រូវសរសេរបំពេញបែបបទសុំប្រឡង ចុះហត្ថលេខា និងមកដាក់ពាក្យដោយខ្លួនឯងផ្ទាល់
- **បេក្ខជន** ត្រូវទៅធ្វើលិខិតបញ្ជាក់ពីសុខភាពនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ករណីជាជនពិការ) និងលិខិតថ្កោលទោសនៅក្រសួងយុត្តិធម៌ ជាបន្ទាន់ក្រោយពីបានប្រឡងជាប់វិញ្ញាសាសរសេរ
- ព័ត៌មានលម្អិត សូមមកទំនាក់ទំនងនៅនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក "ការិយាល័យបុគ្គលិក" រៀងរាល់ម៉ោងធ្វើការ។

អាស្រ័យហេតុនេះ សូមសិស្ស-និស្សិត និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

**កន្លែងទទួល :**

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន សាលារាជធានី ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ
- ឯកសារ-កាលប្បវត្តិ

ជា សុផារ៉ា